# សុន្ទរកថា

## ឯកឧត្តម សូ ឃុន រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

## ក្នុងឱកាសបើកអង្គប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០០៩និងទិសដៅ២០១០របស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## ( នៅថ្ងៃទី ៣១ ខែ មិនា ឆ្នាំ ២០១០ )

**-ឯកឧត្តម-អស់លោក-លោកស្រី-ភ្ញៀវកិត្តិយសទាំងអស់ជាទីស្នេហា!**

តាងនាមរាជរដ្ឋាភិបាលនិងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវសេចក្តីរីករាយ ដោយបានចូលរួមក្នុងពិធីប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០០៩ និង ការលើកទិសដៅឆ្នាំ២០១០ របស់ក្រសួងនាពេលនេះ។ ខ្ញុំសូមស្វាគមន៍ចំពោះវត្តមានដ៏ប្រសើររបស់ឯកឧត្តម-អស់លោក-លោកស្រីទាំងអស់ ដែលបានឆ្លៀតឱកាសចូលរួមដោយផ្ទាល់ក្នុងកិច្ចប្រជុំនេះ។ វត្តមានរបស់យើងទាំងអស់គ្នាពិតជាបញ្ជាក់អោយឃើញថា មានភាពសកម្មចូលរួមអនុវត្តន៍ **"យុទ្ធសាស្ត្រចតុកោណ"** ដំណាក់កាលទី-២ ដែលជារបៀបវីរៈគោលនយោបាយសង្គមសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់និតិកាលទី៤ នៃរដ្ឋសភា និង **"ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០"** ក្នុងគោលដៅ **"ឆ្ពោះទៅរកកំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ"** ក្រោមការដឹកនាំដ៏ភ្លឺស្វាងនិង ឧត្តុង្គឧត្តមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា។

ខ្ញុំសូមកោតសរសើរនិងគាំទ្រដោយស្មោះចំពោះកិច្ចខំប្រឹងប្រែងរបស់គ្រប់ថ្នាក់ដឹកនាំក្រសួង និង បណ្តាឯកឧត្តម-អស់លោក-លោកស្រីជាថ្នាក់ដឹកនាំអង្គភាព ដែលរៀបចំអោយមានកិច្ចប្រជុំរួមគ្នានាពេលនេះ ក្នុងគោលបំណងប្រឹងប្រែងចូលរួមផ្តល់ជាមតិយោបល់សម្រាប់ប្រមូលផ្តុំគំនិត និងបញ្ញាញាណ រួមគ្នាដោះស្រាយនូវបញ្ហាប្រឈមនានា។ តាមរយៈការប្រជុំថ្ងៃនេះខ្ញុំសង្ឃឹមថា ឯកឧត្តម-លោកជំទាវ-អស់លោក-លោកស្រី ខិតខំរិះរកមតិយោបល់ និងអនុសាសន៍ល្អៗអោយបានច្រើន ដើម្បីចែករំលែកបណ្តាបទពិសោធន៍-ការយល់ដឹងពីគ្នាទៅវិញទៅមកដើម្បី បន្តអភិវឌ្ឍន៍វិស័យប្រៃសណីយ៍និងទូរគមនាគមន៍ អោយមានការប្រែប្រួលមួយកម្រិតទៀត ទាំងលើផ្នែកហេដ្ឋា រចនាសម្ព័ន្ធ និងបច្ចេកវិទ្យាទំនើប ឈានទៅដល់កំរិតស្តង់ដាររួមមួយ ក្នុងតំបន់និងសកល។ វិភាគទានពេលវេលា-ចំណេះដឹង-បទពិសោធន៍របស់ឯកឧត្តម-អស់លោក-លោកស្រីក្នុងការចូលរួមសម័យប្រជុំ នេះពិតជាមានតម្លៃ និងអត្ថន័យជ្រាលជ្រៅដោយសារតែយើងទាំងអស់គ្នាមិនត្រឹមតែជួយពិនិត្យមើលវាយតម្លៃការអនុវត្តន៍កន្លងមកប៉ុណ្ណោះទេ។ ប៉ុន្តែប្រាកដជានឹងលើកឡើងនូវបញ្ហាប្រឈមក្នុងការធ្វើសេវាកម្ម-អាជីវកម្មពេលបច្ចុប្បន្ន និង ប្រាកដជានឹងរំលេចឡើងនូវទស្សនៈវិស័យសម្រាប់អភិវឌ្ឍន៍វិស័យទាំងពីរនាពេលខាងមុខផងដែរ។

**-ឯកឧត្តម-អស់លោក-លោកស្រី !**

គោលដៅជាយុទ្ធសាស្ត្ររបស់ក្រសួងគឺ ការបន្តរៀបចំប្រព័ន្ធប្រៃសណីយ៍និងទូរគមនាគមន៍ អោយមានការរីកចំរើនដូចបណ្តាប្រទេសនៅក្នុងតំបន់និងអន្តរជាតិទាំងហេដ្ឋារចនាសម្ព័ន្ធ-បច្ចេកវិទ្យាព័ត៌មាននិងសេវាបន្ថែមផ្សេងៗទៀត ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់-សេវាកម្មទំនើបគ្របដណ្តប់ទូទាំងប្រទេស សំដៅចូលរួមជំរុញកំណើនសេដ្ឋកិច្ច លើកកម្ពស់ជីវភាពរបស់ប្រជារាស្ត្រ។ ពង្រីកសេវាកម្មទៅតំបន់ជនបទ បង្កលក្ខណៈអោយប្រជាជនបានទទួលព័ត៌មាន និងបញ្ជូនព័ត៌មានក្នុងការទំនាក់ទំនងបានឆាប់រហ័ស។ បង្កើនកិច្ចសហប្រតិបត្តិការនិងលើកទឹកចិត្តវិនិយោគឯកជន ចូល

រួមសម្រេចនូវកម្មវិធីទំនើបកម្មវិស័យនេះ។ យកចិត្តទុកដាក់ជំរុញការងារបណ្តុះបណ្តាលធនធានមនុស្ស។

**១.សេវាប្រៃសណីយ៍:**

ក្រសួងបានខិតខំជាបន្តបន្ទាប់ការធ្វើកំណែទម្រង់ប្រព័ន្ធគ្រប់គ្រងដើម្បីបន្តការអភិវឌ្ឍប្រព័ន្ធប្រៃសណីយ៍ប្រកបដោយគុណភាពខ្ពស់ ស្របតាមស្តង់ដារអន្តរជាតិ ជម្រុញអោយមានសេវាកម្មទូទាំងប្រទេស។ ពង្រឹងរចនាសម្ព័ន្ធប្រៃសណីយ៍ព្រមទាំងសមត្ថភាពស្ថាប័នសេវាកម្មត្រូវបានធ្វើឱ្យប្រសើរឡើងដូចជា: ការកាត់បន្ថយពេលចែកបញ្ញើ ការដាក់អោយដំណើរការសេវាឆាប់រហ័សនៅរាជធានីនិងខេត្តការពង្រីកសេវាប្រៃសណីយ៍ដល់តំបន់ទី ប្រជុំជនសំខាន់ៗ-ការបង្កើតប្រព័ន្ធគ្រប់គ្រងតាមដានត្រួតពិនិត្យបញ្ញើដោយប្រើប្រាស់ប្រព័ន្ធ(IPS)ចំពោះបញ្ញើឆាប់រហ័ស ប្រៃសណីយ៍ភ័ណ្ឌ បញ្ញើអនុសិដ្ឋជាដើម....។ល។ ការបញ្ជូន និងទទួលបញ្ញើក្នុងប្រទេសអនុវត្តន៍បាន ០៥ ទៅ ០៦ ជើងក្នុង ០១សប្តាហ៍ និងទៅអន្តរជាតិបាន ០៥ជើងក្នុង ០១សប្តាហ៍។ ការប្តូរបញ្ញើផ្ទៃរាបតាមច្រកអន្តរជាតិប៉ោយប៉ែត (បន្ទាយមានជ័យ) ជាមួយប្រៃសណីយ៍ថៃ និង បាវិត(ស្វាយរៀង) ជាមួយប្រៃសណីយ៍វៀតណាមបានពី ០៣ ទៅ ០៤ ជើងក្នុង០១ខែ។ បង្កើតអោយមានសេវាអណត្តិប្រៃសណីយ៍ ក្នុងប្រទេស និងអន្តរជាតិ-ការផ្ញើប្រាក់តាមប្រព័ន្ធអេឡិចត្រូនិច និងបញ្ញើផ្សព្វផ្សាយពាណិជ្ជកម្ម។ ក្រសួងបានផ្តល់អាជ្ញាបណ្ណ័សេវាឆាប់រហ័សអន្តរជាតិដល់ក្រុមហ៊ុនចំនួន ២២ និង ចំនួន ០៥ ភ្នាក់ងារប្រៃសណីយ៍ ដែលកំពុងធ្វើសេវាកម្មនៅកម្ពុជា។ ជាមធ្យមអត្រានៃការប្រើប្រាស់សេវាប្រៃសណីយ៍នៅភ្នំពេញស្មើ ១,៧០ និងខេត្តស្មើ ០,០៣ ក្នុងប្រជារាស្ត្រ០១នាក់ ក្នុង០១ឆ្នាំ ។អាត្រានៃការប្រើប្រាស់សេវាបញ្ញើអន្តរជាតិស្រូបយកប្រមាណ៩២ ភាគរយនៃសេវាទូទាំងប្រទេស។

**២.សេវាទូរគមនាគមន៍:**

២-១-គិតត្រឹមថ្ងៃទី៣១ខែធ្នូឆ្នាំ២០០៩អាត្រាប្រើប្រាស់(ទូរស័ព្ទចល័ត-អចល័ត) ស្មើ៤០.៩៥សម្រាប់ប្រជារាស្ត្រ១០០នាក់ទូទាំងប្រទេស។ ដែលក្នុងនោះ (១) ទូរស័ព្ទអចល័តស្មើនឹង០.៦៤ សម្រាប់ប្រជារាស្ត្រ១០០នាក់ស្មើ១០០.៨៨៧គ្រឿង(២) ទូរស័ព្ទចល័តស្មើ៣៩.៩៥សម្រាប់ប្រជារាស្ត្រ១០០នាក់ស្មើ ៦.៣៤៦.៧២០គ្រឿង។

-ទូរគមនាគមន៍កម្ពុជានិងបណ្តាក្រុមហ៊ុនជាដៃគូអាជីវកម្មជាមួយក្រសួង បានដាក់អោយប្រើប្រាស់ទូរស័ព្ទចល័ត និងអចល័តសរុបចំនួន ៦.៤៤៧.៦០៧គ្រឿង និងទូរស័ព្ទសាធារណៈចំនួន៤៥៦គ្រឿង។

-សេវា Internet: មានអតិថិជនកំពុងប្រើប្រាស់ចំនួន ២៩១,៩៨៩នាក់។

-ផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនជាតិ និង អន្តរជាតិ ក្នុងការធ្វើអាជីវកម្មទូរស័ព្ទចល័ត-អចល័តនិងសេវាមួយចំនួនទៀតដូចជា សេវាទូរស័ព្ទតាមប្រព័ន្ធ Internet(ISP) និងសេវា(VOIP)។

២-២-គុណភាពបណ្តាញនិងសេវាត្រូវបានពង្រឹងឥតឈប់ឈរ។ ប្រភេទទូរស័ព្ទអចល័តមានការអភិវឌ្ឍន៍ពង្រីកការប្រើប្រាស់ជាបន្តបន្ទាប់ ពិសេសនៅទីក្រុងភ្នំពេញនិងតាមបណ្តាខេត្តដែលមានបណ្តាញកាប្លឺអុបទិក។ រីឯប្រភេទទូរស័ព្ទចល័តវិញបានគ្របដណ្តប់ដល់ទីប្រជុំជន និង ទីជនបទក្នុង អត្រាពី៦០ទៅ៨០ភាគរយ។

២-៣-ការងារសហប្រតិបត្តិការនិងការវិនិយោគទុនក៏ជាប្រភពមួយ ដ៏មានប្រសិទ្ធិភាពក្នុងការបំពាក់នូវឧបករណ៍សម្ភារៈតាមបច្ចេកវិទ្យាទំនើប ដោះស្រាយបាននូវសំណូមពរប្រើប្រាស់ បានទាន់ពេលវេលា និង ពង្រីកបាននូវសមត្ថភាពជំនាញផងដែរ។ តម្លៃសេវាទូរគមនាគមន៍ត្រូវបានធ្វើការកែសម្រួលជាបន្តបន្ទាប់។

២-៤-ក្រសួងកំពុងយកចិត្តទុកដាក់ជម្រុញការអនុវត្តន៍គម្រោងធំៗចំនួន០៣ ដែលពាក់ពន្ធ័ដល់កិច្ចអភិវឌ្ឍន៍ទូរគមនាគមន៍ជនបទ ដោយប្រើប្រាស់កម្ចី និងការវិនិយោគរបស់បរទេសដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធកាប្លឺ

អុបទិកសំដៅពង្រីកសេវាកម្មទូរគមនាគមន៍ទូទាំងប្រទេស :

**គម្រោងទី១:** បណ្តាញទូរគមនាគមន៍មហាអនុតំបន់ទន្លេមេគង្គរបស់ JICA ក្រោមក្របខ័ណ្ឌ គម្រោងប្រាក់កម្ចីអភិវឌ្ឍន៍ CP-P5 ដើម្បីស្ថាបនាហេដ្ឋារចនាសម្ព័ន្ធបណ្តាញទូរគមនាគមន៍ក្នុងរបៀងរីកចម្រើននៃកម្ពុជា (Cambodia Growth Corridor) ។តំបន់គ្របដណ្តប់នៃគម្រោងនេះគឺត្រូវវាយបណ្តោយខ្សែកាប្លិ៍អុបទិកតាមកំណាត់ផ្លូវជាតិលេខ ០៦(កំពង់ចាម-ភ្នំពេញ) ផ្លូវជាតិលេខ ០២-០៣ សំដៅទៅតាកែវ កែប កំពត និងតាមបណ្តោយកំណាត់ផ្លូវជាតិលេខ៤ ឆ្ពោះទៅខេត្តព្រះសីហនុ មានប្រវែងសរុបប្រមាណជាង ៤០០គ.ម ។

**គម្រោងទី២:** ការស្ថាបនាបណ្តាញទូរគមនាគមន៍ព័ត៌មានឆ្លងកាត់មហាអនុតំបន់ទន្លេមេគង្គ GMS-IS ក្របខណ្ឌ័ឥណទានសម្បទានពី China Exim Bank ។ការវាយបណ្តាញខ្សែកាប្លិ៍អុបទិកពីស្ទឹងត្រែងទៅ សៀមរាប និងពីកំពង់ចាមទៅមាត់ច្រកអន្តរជាតិត្រពាំងគ្រៀល (ខេត្តស្ទឹងត្រែង) ប្រវែងសរុប ៦៥១គ.មព្រមទាំងសាងសង់អគារស្ថានីយ៍ចំនួន ១៩កន្លែងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ០៦ និងលេខ ០៧ ។គម្រោងនេះបានបញ្ចប់ជាស្ថាពរកាលពីថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៩ ហើយពិធីសម្ពោធដាក់អោយធ្វើសេវាកម្មជាផ្លូវការបានប្រព្រឹត្តិទៅកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៩ កន្លងទៅ ។

**គម្រោងទី៣:** ការកសាងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ក្នុងប្រទេស ដោយប្រើបណ្តាញកាប្លិ៍អុបទិកជាការវិនិយោគរបស់ក្រុមហ៊ុនCFOCN ។ ក្នុងគម្រោងកប់កាប្លិ៍ប្រវែង៨.៥៨៣គ.ម ដំណាក់កាលទី១សម្រេចការជីកវាយបណ្តាញកាប្លិ៍ក្រោមដី បាន២.២០០គ.មរួចហើយ តាមផ្លូវជាតិលេខ១-លេខ២-លេខ៤-លេខ៥-លេខ៦-លេខ៧និងរាជធានីភ្នំពេញ ។ហើយបច្ចុប្បន្នមានក្រុមហ៊ុនទូរស័ព្ទមួយចំនួនបានជួលជាវបណ្តាញប្រើប្រាស់ហើយដូចជា: Telcotech,Ltd -Sotelco,Ltd- M.fone-EZEcom.

២-៥-តាមរយៈឥណទានកម្ចីនិងការវិនិយោគបរទេស បណ្តាញខ្សែកាប្លិ៍អុបទិកប្រវែងប្រមាណ ១៥,៣៤០គម.បានស្ថាបនារួចរាល់ជាស្ថាពរ កំពុងដាក់ឱ្យដំណើការទូទាំងប្រទេស ។ បណ្តាក្រុមហ៊ុនជាដៃគូ បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍វិស័យនេះធ្វើឱ្យមានទំនើបកម្មនិងបច្ចេកវិទ្យាថ្មីៗការប្រើប្រាស់បច្ចេកវិទ្យាកំព្យូទ័រនិងអ៊ិនធើណែត បានរីកសាយយ៉ាងលឿនជាមួយនិងការកើនឡើងយ៉ាងឆាប់រហ័ស នៃចំណេះដឹងជំនាញក្នុងវិស័យនេះ នៅក្នុងស្រទាប់យុវជនផងដែរ ។

៣-បច្ចុប្បន្នយើងអាចវាយតម្លៃបានថាសេវាប.ទប្រាកដជាមានការរីកចំរើនមួយកំរិតផ្នែកមូលដ្ឋានសម្ភារៈទាំងលើហេដ្ឋារចនាសម្ព័ន្ធនិងបច្ចេកវិទ្យាទំនើប ។ ប៉ុន្តែក៏នៅមានផ្នែកខ្លះពុំទាន់បានសុក្រឹត្យនិងគ្រប់ជ្រុងជ្រោយដែរ ។ ផ្តើមចេញពីកត្តាទាំងនេះ យើងត្រូវបន្តការខិតខំលើកកំពស់ស្មារតីទទួលខុសត្រូវក្នុងវិជ្ជាជីវៈ ដើម្បីអភិវឌ្ឍន៍វិស័យទាំងពីរនេះអោយបានកាន់តែប្រសើរ អាចជាវិស័យមួយ ដែលមានសមត្ថភាពសមស្របដើម្បីរួមចំណែក ដល់ការជម្រុញកំណើនសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាព ដើម្បីកាត់បន្ថយភាពក្រីក្រដែលជាប្រធានបទដ៏មានសារៈសំខាន់ និង ជាយុទ្ធសាស្រ្តរបស់រាជរដ្ឋាភិបាល ។

**៤-បញ្ហាប្រឈម:** ស្របជាមួយបណ្តាសមិទ្ធិផលដែលបានកើតមាននេះ ។នារយៈពេលកន្លងមកវិស័យទាំងពីររបស់យើងក៏លេចចេញបណ្តាបញ្ហាប្រឈមជាច្រើនផងដែរ ដែលបញ្ហាទាំងអស់នោះ វាក៏ជាបទពិសោធន៏សម្រាប់ធ្វើការដោះស្រាយជាបន្តទៀត ។ មានដូចជា:

+ច្បាប់ស្តីពីវិស័យប្រៃសណីយ៍បានដាក់អោយប្រើប្រាស់ ។ប៉ុន្តែប្រសិទ្ធភាពអនុវត្តន៏នៅមិនទាន់បាន

រលូនដោយសង្កេតឃើញថា ការធ្វើអាជីវកម្មទទួលដឹកបញ្ញើមានគ្រប់ទីកន្លែងពិសេសមធ្យោបាយរបស់ឯកជន។

+សេវាប្រៃសណីយ៍របស់ក្រុមហ៊ុនឯកជនមានលក្ខណៈប្រកួតប្រជែងខ្លាំងជាងសេវាប្រៃសណីយ៍របស់រដ្ឋបណ្ដាញប្រៃសណីយ៍ពុំទាន់បានពង្រីកដល់ទីជនបទដាច់ស្រយាល។

+វិស័យប្រៃសណីយ៍ពុំទទួលបាននូវស្វ័យភាព ខាងបច្ចេកទេស-រដ្ឋបាល-ហិរញ្ញវត្ថុ-ការផ្ដល់ទុនពុំគ្រប់គ្រាន់ឬឃឹតយូរមិនអាចមានលទ្ធភាពគ្រប់គ្រាន់ធ្វើការប្រកួតប្រជែងជាមួយក្រុមហ៊ុនឯកជននានាបាន។

+ប្រសិទ្ធភាពនៃការគ្រប់គ្រងវិស័យទូរគមនាគមន៍នៅមានកម្រិតដោយសារច្បាប់ ស្ដីពីវិស័យទូរគមនាគមន៍ពុំទាន់ទទួលបានការអនុម័តពីអង្គការនីតិប្បញ្ញត្តិ។

+កិច្ចសហការរវាងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងប្រតិបត្តករ-ភ្នាក់ងារអភិវឌ្ឍន៍នៅពុំទាន់មានភាពល្អប្រសើរនៅឡើយ។

+ការអនុវត្តន៍ច្បាប់ឬលិខិតបទដ្ឋានដែលកំពុងមានជាធរមានពុំទាន់ត្រូវបានទទួលលទ្ធផលដូចរំពឹងទុក

+កិច្ចអភិវឌ្ឍន៍ធនធានមនុស្ស អោយដើរទាន់ការអភិវឌ្ឍវិស័យបច្ចេកទេសទាំង០២នៅមានកម្រិត។

**-ឯកឧត្ដម-អស់លោក-លោកស្រី**

អង្គប្រជុំថ្ងៃនេះពិតជាការជួបជុំគ្នាមួយដែលប្រកបដោយប្រធានបទល្អៗ និង បទពិសោធន៍ជាច្រើន ដែលនឹងលើកយកមកពិភាក្សា។ ខ្ញុំសូមអោយអស់លោក-លោកស្រីយកចិត្តទុកដាក់ និងជួយរំលេចឡើងនូវបណ្ដាវិធានការជាក់ស្ដែង-ដើម្បីសម្រេចបានរាល់ទិសដៅដែលបានលើកឡើង។

ការពិភាក្សាលើកនេះខ្ញុំសូមការយោគយល់អំពីឯកឧត្ដម-អស់លោក-លោកស្រីជាសមាជិក-សមាជិការ នៃកិច្ចប្រជុំទាំងមូលគួរផ្ដល់ពេលវេលាអោយបានច្រើនបំផុត ជូនដល់អស់លោក-លោកស្រីតំណាងមន្ទីរប.ទខេត្ត និងតំណាងក្រុមហ៊ុនដៃគូដែលជាប្រតិបត្តិករបានឡើងធ្វើបទអន្ដរាគមន៍អោយបានច្រើនដើម្បីសម្ដែងមតិយោបល់រួម ចំណែកធ្វើការពាក់ព័ន្ធអំពីគោលនយោបាយនិងគម្រោងអភិវឌ្ឍន៍វិស័យប្រៃសណីយ៍និងទូរគមនាគមន៍។ ព្រោះថាការប្រកួតប្រជែងវិស័យឯកជនធ្វើអោយបច្ចេកវិទ្យាទូរគមនាគមន៍ មានសន្ទុះរីកចម្រើនជឿនលឿនស្ទានពុំដល់-ឯកម្លាំងទីផ្សារសកលភាវូបនីយកម្មក៏កាន់តែរីកធំធាត់ ទាមទារចាំបាច់អោយទីផ្សារទូរគមនាគមន៍នៅកម្ពុជា ត្រូវរ៉ាប់រងកាតព្វកិច្ចខិតខំសម្រេចកិច្ចការរបស់ខ្លួនអោយបានសមស្របតាមក្របខ័ណ្ឌការងារឯកជនភាវូបនីយកម្ម-សេរីភាវូបនីយកម្ម ក្នុងតំបន់ក្នុងសមត្ថកិច្ចជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។ ផ្ដើមចេញពីការធ្វើកិច្ចសហប្រតិបត្តិការរកស៊ីរួមគ្នានិងការធ្វើជាដៃគូជាមួយគ្នា អាចធានាបាននូវការផ្លាស់ប្ដូរបទពិសោធន៍-បច្ចេកវិទ្យាទំនើបធ្វើអោយវិស័យទាំងពីរមិនត្រឹមតែទទួលបានការពេញនិយមក្នុងការប្រើប្រាស់និងឈានទាន់ទៅនិងចរន្ដរីកចម្រើនក្នុងតំបន់និងអន្តរជាតិតែប៉ុណ្ណោះទេ។ តែក៏ជាកំលាំងចលករជម្រុញដល់ការ វិវត្តន៍យ៉ាងឆាប់រហ័សចំពោះធនធានមនុស្សផងដែរ។

ក្នុងបទអន្ដរាគមន៍ខ្ញុំសង្ឃឹមថា អស់លោក-លោកស្រីជាតំណាងទាំងអស់ និងលើកយកបញ្ហាគន្លឹះៗមួយចំនួនដែលខ្ញុំយល់ថាជាការចាំបាច់ដែលត្រូវយក មកធ្វើជាប្រធានបទសម្រាប់ធ្វើការពិភាក្សាដែលមានជាអាទិ៍គឺៈ

១-អំពីស្ថានភាពការធ្វើសេវាកម្ម-អាជីវកម្ម។ប្រសិទ្ធភាពនៃការអនុវត្តន៍រាល់លិខិតបទដ្ឋានពាក់ព័ន្ធដល់វិស័យទាំងពីរដែលកំពុងនៅជាធរមាន។យុទ្ធសាស្ត្រនៃការដោះស្រាយបញ្ហាប្រឈមនានា។

២-ក្នុងការធ្វើវិនិយោគនឹងក្នុងភាពជាដៃគូរពីវិស័យប្រៃសណីយ៍និងទូរគមនាគមន៍តើរដ្ឋឬក្រសួងមាននៅសេសសល់អ្វីខ្លះទៀតដែលពុំទាន់ធ្វើកិច្ចសហការបានគ្រប់ជ្រុងជ្រោយនៅឡើយ។

៣-ដើម្បីអោយកិច្ចសហប្រតិបត្តិការ-ការទំនាក់ទំនងមានភាពរលូនធានាបានដល់ការរួមចំណែកដល់កិច្ចអភិវឌ្ឍន៍វិស័យប.ទតើអស់លោក-លោកស្រីមានសំណូមពរអ្វីខ្លះចំពោះក្រសួង-ចំពោះក្រុមហ៊ុនជាដៃគូរនិងក្រុមហ៊ុនរួមអាជីពជាមួយគ្នា។

៤-ក្នុងនោះដែរខ្ញុំរំពឹងថា អស់លោក-លោកស្រី លើកឡើងផងដែរអំពីបណ្តាបទពិសោធន៍ល្អៗដែលនាំមកនូវភាពជោគជ័យក្នុងការអនុវត្តន៏ផែនការឬក្នុងកិច្ចការវិនិយោគកន្លងមកដើម្បីចែករំលែកជូនដល់សមាជិក-សមាជិកាអង្គប្រជុំទទួលបានបទពិសោធន៏សម្រាប់ការដឹកនាំគ្រប់គ្រងធ្វើសេវាកម្ម-អាជីវកម្ម...។ល។

ជាទីបញ្ចប់ ជំនួសមុខអោយថ្នាក់ដឹកនាំក្រសួងនិងមន្ត្រីរាជការទាំងអស់របស់ក្រសួង ខ្ញុំសូមបួងសួងចំពោះទេវតានិងវត្ថុស័ក្តិសិទ្ធក្នុងលោកមេត្តាជួយប្រសិទ្ធិពរជ័យបវរប្រសើរជូនចំពោះឯកឧត្តម-លោក-លោកស្រី-សមាជិកសមាជិការនៃអង្គប្រជុំតំណាងក្រុមហ៊ុនជាដៃគូទាំងអស់មានវត្តមានទីនេះសូមជួបប្រទះនិងពុទ្ធពរទាំង០៤ប្រការគឺអាយុ វណ្ណៈសុខៈពលៈ កុំបីឃ្លៀងឃ្លាត-សូមអោយកិច្ចដំណើរការអង្គប្រជុំថ្ងៃនេះប្រព្រឹត្តទៅប្រកបដោយផ្លែផ្កា-ជោគជ័យ។

ខ្ញុំសូមប្រកាសបើកកិច្ចប្រជុំចាប់ពីពេលនេះតទៅ....។

*សូមអរគុណ!*